Sabrina

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងបន្ថែម

## ស្តីពី

## ការកំណត់ប្រាក់ឈ្នួល សំរាប់កម្មករនិយោជិតផ្នែកបោះពុម្ពក្នុងកំឡុងពេលព្យួរការងារជាបណ្ដោះអាសន្ន

យោង: -សេចក្ដីណែនាំ លេខ ០៤៥/២០ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០២០ របស់ក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ ស្ដីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស សម្រាប់ រោងចក្រ សហគ្រាស គ្រឹះស្ថាន ក្នុងវិស័យកាត់ដេរ និង ទេសចរណ៍ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដោយសារជំងឺកូវីដ-១៩

-អនុសញ្ញារួម រវាងក្រុមហ៊ុន និងតំណាងសហជីព ស៊ីខៅឌូ ប្រចាំក្រុមហ៊ុនចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩

-សំណើររបស់សហជីព (ស៊ីខៅឌូ) ដែលមានភាពតំណាងបំផុត ប្រចាំក្រុមហ៊ុន

ដោយការរីករាលដាលនៃជំងឺកូវីដ-១៩ បានបង្កនូវផលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការផលិតកម្ម របស់ក្រុមហ៊ុន និង ការធ្លាក់ចុះនូវការបញ្ជាទិញរបស់អ្នកបញ្ជាទិញ បានធ្វើអោយក្រុមហ៊ុន (សាប្រ៊ីណា ខេមបូឌា) មានការខាត់បង់ និង ពុំមានលទ្ធភាពក្នុងការផ្ដល់ការងារជូនដល់បងប្អូនកម្មករនិយោជិត នៅតាមក្រុម ឬ ផ្នែក មួយចំនួន ។

ដើម្បីស្រោចស្រង់ស្ថានការណ៍ និង ធ្វើយ៉ាងណាកុំឱ្យប៉ះពាល់ដល់ផ្នែក ឬ ក្រុមផ្សេងៗ ជាពិសេស ប៉ះពាល់ដល់ក្រុមហ៊ុនទាំងមូលហេតុដូច្នេះ ក្រុមហ៊ុន សាប្រ៊ីណា និង សហជីព ស៊ីខៅឌូ ដែលមានភាពតំណាង បំផុតប្រចាំក្រុមហ៊ុន បានប្រជុំពិភាក្សាជាមួយកម្មករនិយោជិតក្នុងផ្នែកដែលទទួលរងការប៉ះពាល់តាមរយៈតំណាង របស់ពួកគាត់ និង បានឯកភាពគ្នាដូចខាងក្រោម៖

ប្រការ១ : ភាគីទាំងពីរ បានព្រមព្រៀងគ្នាថានឹងធ្វើការព្យួរការងារជាបណ្ដោះអាសន្ន សម្រាប់កម្មករនិយោជិត ក្នុង ផ្នែកបោះពុម្ព ទាំងអស់ ។

ប្រការ២ : ការព្យួរការងារជាបណ្ដោះអាសន្ន នេះ នឹងធ្វើឡើងលើកម្មករនិយោជិត ចំនួន **៦៩នាក់** សម្រាប់ រយៈពេលចំនួន ១ខែ ពោលពី ថ្ងៃទី០១ ខែសីហា រហូតដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ ។

ប្រការ៣ : ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថមជូនកម្មករនិយោជិតចំនួន សាមសិប (៣០) ដុល្លាអាមេរិចបន្ថែមពីលើប្រាក់ឧបត្ថមរបស់រដ្ឋាភិបាល។

ប្រការ៤ : កិច្ចព្រមព្រៀងទាំងឡាយណាផ្ទុយពីខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ៥ : កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាព និងអនុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃអង្គារ ២រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅសាប្រ៊ីណា ថ្ងៃទី៧ ខែ កក្កដា ឆ្នាំ ២០២០

សហជីព ប្រជាធិបតេយ្យកម្មករកាត់ដេរ
(សហជីព ស៊ីខៅខ្ញូ) ប្រចាំ ក្រុមហ៊ុន សាប្រ៊ីណា

| ប្រធាន | អនុប្រធាន | លេខាធិការ |
|---|---|---|
| ឈោ វិនុត | ឆន សុខយឿន | យី សារ៉ាត |

ក្រុមហ៊ុន សាប្រ៊ីណា
**នាយិកាក្រុមហ៊ុន**

ឈិន ស៊ីងអ៊ីង